# ចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់គ្រួសារនៅជនបទ ពាក់ព័ន្ធនឹងទឹកស្អាត សុខភាព និងអនាម័យ[១]

## សេចក្តីផ្តើម

តាំងពីចុងទសវត្សរ៍ ១៩៧០ ដល់ពាក់កណ្តាលទសវត្សរ៍ ១៩៩០ ប្រទេសកម្ពុជាបានផ្តោតលើសកម្មភាពដោះស្រាយទឹកស្អាត និងអនាម័យដ៏ចាំបាច់នៅជនបទ តាមរយៈការផ្តល់ជំនួយសង្គ្រោះបន្ទាន់។ ការពង្រីកដែនគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាត ហេដ្ឋារចនាសម្ព័ន្ធបង្គន់ទឹកកខ្វក់ចេញ និងបង្កើនអនាម័យតាមគ្រួសារ បានលូតលាស់ទៅមុខយឺតៗនៅឡើយ។ ទិន្នន័យទទួលបានពីដំបូងៗបង្ហាញថា ប្រព័ន្ធអនាម័យនៅជនបទមានដែនគ្របដណ្តប់តូចណាស់ត្រឹម ២% ប៉ុណ្ណោះនៅឆ្នាំ១៩៩៥ និង ៨% នៅឆ្នាំ២០០២ (Rosenboom 2011) ប៉ុន្តែបន្ទាប់ពីនោះមកវាក៏កើនឡើង និងកើនយ៉ាងគំហុកដល់ ១៤% នៅឆ្នាំ២០០៤ និងជិតដល់ ២២% នៅឆ្នាំ២០០៥ (World Bank 2008)។ អង្កេតកម្រិតជាតិស្តីពី ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) សុខភាព និងអនាម័យ របស់ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្នុង ១២ខេត្ត នៅឆ្នាំ២០១០ បានរកឃើញថា មានតែ គ្រួសារ ២៩,៦% ប៉ុណ្ណោះ ដែលមានបង្គន់ប្រើប្រាស់។

ការមានទឹកស្អាតសម្រាប់ហូបមិនគ្រប់គ្រាន់ និងការអនុវត្តរបៀបរក្សាសុខភាពនិងអនាម័យ (S&H) អន់ខ្សោយ វាបង្កការខាតបង់ដល់សេដ្ឋកិច្ចកម្ពុជា។ អនាម័យអន់ខ្សោយ បានបង្កការខាតបង់ដល់សេដ្ឋកិច្ច អស់ប្រមាណ ៤៤៨លានដុល្លារ/ឆ្នាំ ស្មើនឹងប្រហែល ៣២ដុល្លារក្នុងមនុស្សម្នាក់ ឬ ៧,២% នៃផសស កម្ពុជា នៅឆ្នាំ២០០៥ (World Bank 2008)។ ម្យ៉ាងទៀត មានកុមារកម្ពុជាអាយុក្រោម ៥ឆ្នាំ ដល់ ១៧% ត្រូវស្លាប់ដោយសារជំងឺរាគរូស ដែលបណ្តាលពីទឹកកខ្វក់ និងកង្វះអនាម័យ (Mom 2011)។ ទោះជាភាពក្រីក្របានធ្លាក់ចុះពី ៣០,១% នៅឆ្នាំ២០០៧ ដល់ ២៧,២% នៅឆ្នាំ២០១០ ក្តីក៏វិនិយោគរបស់គ្រួសារលើប្រព័ន្ធអនាម័យ នៅតែមានកម្រិតទាប។ ដោយសារមានប្រជាជនជាង ៨០% រស់នៅតាមតំបន់ជនបទ ការកែលំអស្ថានភាពសុខភាពនិងអនាម័យនៅជនបទ ជាកត្តាចាំបាច់បំផុតដើម្បីកាត់បន្ថយ ភាពក្រីក្រ និងបង្កើនសុខមាលភាពសង្គម ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគូសបញ្ជាក់ពី សារៈសំខាន់នេះថា "នៅកម្ពុជា បញ្ហាសុខភាពនិងអនាម័យអន់ខ្សោយ ជាកត្តាមួយ ដែលរួមចំណែកដល់ភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងរាំងស្ទះដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ" (World Bank 2008: 5)។

ឥឡូវនេះ រដ្ឋាភិបាលមានស្ថានភាពកាន់តែប្រសើរដើម្បីផ្តោតកិច្ចប្រឹងប្រែងឲ្យបានកាន់តែច្រើនលើ ការផ្តួចផ្តើមគំនិតរយៈពេលវែង សំដៅកសាងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងបង្គន់ទឹកកខ្វក់ចេញនៅជនបទ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈបង្កើនការអនុវត្ត S&H។ លទ្ធភាពបានប្រើប្រាស់ទឹកស្អាតនិងបង្គន់ និងការលើកកម្ពស់ការអនុវត្ត S&H បានទទួលអាទិភាពខ្ពស់ និងមានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (CDC 2011)។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទី៧ (ធានានិរន្តរភាពបរិស្ថាន) មានគោលដៅផ្តល់លទ្ធភាពបានប្រើប្រាស់ទឹកស្អាតដល់ ៥០% និងសេវាអនាម័យកាន់តែប្រសើរដល់ ៣០% នៃប្រជាពលរដ្ឋនៅជនបទ នៅត្រឹមឆ្នាំ២០១៥។ ដើម្បីគាំទ្រដល់អាទិភាពទាំងនេះ គោលនយោបាយជាតិស្តីពីទឹកស្អាតនិងអនាម័យ បានតាក់តែងឡើងនៅឆ្នាំ២០០៣ ដោយមានគូសបញ្ជាក់ពីចក្ខុវិស័យច្បាស់លាស់របស់រដ្ឋាភិបាលដែលកំណត់ថា "ជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានលទ្ធភាពយូរអង្វែងក្នុងការទទួលបានការផ្គត់ផ្គង់ទឹកស្អាត សេវាអនាម័យ និងបានរស់នៅក្នុងបរិស្ថានមួយមានអនាម័យល្អនៅត្រឹមឆ្នាំ២០២៥" (World Bank 2008: 9)។

## សារៈនៃការសិក្សា

ដើម្បីពង្រឹងនិងបំផុសការអនុវត្ត S&H នៅតាមសហគមន៍ជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) បានបង្កើតកម្មវិធីកែលំអសុខភាពនិងអនាម័យនៅជនបទកម្ពុជា (CR-SHIP) ដោយរួមសហការជាដៃគូជាមួយអង្គការ ភ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) និងមានការឧបត្ថម្ភថវិកាពី មូលនិធិអនាម័យសាកល (Global Sanitation Fund: GSF) នៃក្រុមប្រឹក្សាសហប្រតិបត្តិការអនាម័យ និងការផ្គត់ផ្គង់ទឹក (Water Supply and Sanitation Collaborative Council: WSSCC)។ CR-SHIP មានគោលដៅបង្កើនលទ្ធភាពទទួលបានសេវាអនាម័យកាន់តែល្អប្រសើរ និងការអនុវត្តអនាម័យបានកាន់តែសមស្រប ដោយ ១) លើកទឹកចិត្តឲ្យប្រជាជនប្រើបង្គន់យ៉ាងទៀងទាត់ លាងដៃជាមួយសាប៊ូ និងមានទឹកស្អាតហូបនៅតាមសហគមន៍ជនបទ និង ២) កសាង និងពង្រឹងសមត្ថភាពរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដើម្បីលើកកម្ពស់ការអនុវត្ត S&H ឲ្យបានកាន់តែប្រសើរ។

វិទ្យាស្ថាន CDRI បានធ្វើអង្កេតជាមូលដ្ឋានមួយនៅខេត្តកំពង់ចាម កណ្តាល ស្វាយរៀង តាកែវ និង កំពង់ស្ពឺ ដើម្បីសិក្សាពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) តាមគ្រួសារនៅជនបទ ស្តីពី ទឹកហូបស្អាតនិងការស្តុកទឹក ការសាងសង់និងប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារ និងការអនុវត្តអនាម័យ

[១] អត្ថបទនេះរៀបរៀងដោយកញ្ញា វង្ស ស្រីទូច ជាអ្នកស្រាវជ្រាវ ក្នុងកម្មវិធីអភិវឌ្ឍន៍សង្គមនៃ វិទ្យាស្ថាន CDRI។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អង្គការ ភ្លែន កម្ពុជា ដែលបានឧបត្ថម្ភគាំទ្រដល់គម្រោងនេះ។

[២] ឃុំ គឺជាឯកតាត្រូវយកមកគណនា ដើម្បីកំណត់ថា តើតំបន់នោះស័ក្តិសមជា "ទីប្រជុំជន" ឬ "ជនបទ"។ ធម្មតា សង្កាត់ សំដៅដល់ ឃុំរបស់ទីក្រុង ប៉ុន្តែបើប្រើប្រាស់និយមន័យឆ្នាំ២០០៤នោះ សង្កាត់នៅក្នុងក្រុងទាំង ២៦ នៅកម្ពុជាមិនសុទ្ធតែគ្រប់លក្ខណៈជាតំបន់ទីប្រជុំជនទាំងអស់ទេ។ សូមមើល http://db.ncdd.gov.kh/cdbonline/home/index.castle (accessed 26 May 2012)

ដើម្បីបង្កើតជាព័ត៌មានគោលសម្រាប់ CR-SHIP។ អត្ថបទនេះរាយការណ៍ពីគំហើញសំខាន់ៗ ព្រមទាំងអនុសាសន៍មួយចំនួនដើម្បីកែលំអប្រសិទ្ធភាពនៃការផ្សព្វផ្សាយលើកកម្ពស់ S&H នាពេលបច្ចុប្បន្ន និងជំរុញការទទួលយករបៀបអនុវត្តន៍ S&H ឲ្យបានកាន់តែប្រសើរ ។

## វិធីសាស្ត្រ

ក្រុមស្រាវជ្រាវបានប្រើប្រាស់ទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព ដែលរួមមាន អង្កេតលើ ៨៤១ គ្រួសារជ្រើសរើសដោយចៃដន្យ កិច្ចសម្ភាសន៍ពាក់កណ្តាលរៀបរយ និងការពិនិត្យសង្កេតផ្ទាល់។ ការប្រមូលព័ត៌មានបែបបរិមាណ បានធ្វើឡើងតាមរយៈ ២០ បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) និង ៤០ ការពិភាក្សាតាមក្រុមស្នូល (FGDs)។ KIIs ជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ មាតាបិតាសិស្សនិងលោក/អ្នកគ្រូ ព្រមទាំងមណ្ឌលសុខភាពតាមមូលដ្ឋាន និងបុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD) ដែលបានផ្តល់គំនិតទូលំទូលាយអំពីប្រសិទ្ធភាពជាទូទៅនៃការអនុវត្ត S&H នៅក្នុងតំបន់ចុះសិក្សា។ FGDs ធ្វើឡើងជាមួយ ក្រុមនារីសុទ្ធ ក្រុមនារីនិងបុរសចម្រុះគ្នា លោក/អ្នកគ្រូ និងសិស្សសាលាបឋមសិក្សា បានផ្តល់ព័ត៌មានលំអិតពីបញ្ហាទាក់ទិននឹងការអនុវត្ត S&H ជាក់ស្តែងតាមគ្រួសារ។ ដោយមានជំនួយពីបុគ្គលិក PDRD ទិន្នន័យអង្កេតបានប្រមូលយកក្នុងរយៈពេលជាង ១០ថ្ងៃ ចាប់ពីថ្ងៃទី២៧ វិច្ឆិកា ដល់ ០៦ ធ្នូ ២០១១។ ទិន្នន័យអង្កេត បានយកមកចាត់ចែងតាមកម្មវិធីកុំព្យូទ័រ SPSS និងបម្លែងជា STATA ដើម្បីវិភាគ។

## របកគំហើញ

### *ការប្រើប្រាស់ និងសាងសង់បង្គន់តាមគ្រួសារ*

គ្រួសារគំរូតាងជាងពាក់កណ្តាល (៦០,១៧%) គ្មានបង្គន់ទេ ដូច្នេះ ជិត ៤០% គឺមានបង្គន់ប្រភេទណាមួយ។ អ្នកមានបង្គន់ភាគច្រើន (៩៧,៣១%) គេមានបង្គន់បានកែលំអ ដូចជាបង្គន់ដែលបង្ហូរចូលទៅក្នុងអាងស្តុក (តារាង ១)។ ក្នុងចំណោមអ្នកមានបង្គន់ មាន ៩៦,៤២% បញ្ជាក់ថា បង្គន់របស់ខ្លួនដំណើរការបានធម្មតា (តារាង ១) និងមាន ៥% ប្រាប់ថា នេះមិនមែនជាបង្គន់ទី១ ដែលគាត់ធ្លាប់មាននោះទេ ដូច្នេះ មានជាច្រើនគ្រួសារណាស់ដែលទើបបានធ្វើបង្គន់ប្រើជាលើកដំបូង។

តារាង ១៖ បង្គន់តាមគ្រួសារ បែងចែកតាមប្រភេទ (n=335)

| ប្រភេទបង្គន់តាមគ្រួសារ | ប្រភេទ |
|---|---|
| *បានកែលំអ* | |
| បង្គន់ចាក់ទឹកតទៅប្រព័ន្ធទឹកសំអុយ | 0.6 |
| បង្គន់ដែលបង្ហូរចូលទៅក្នុងអាងស្តុក | 97.31 |
| សរុប | 97.91 |
| *មិនបានកែលំអ* | |
| បង្គន់ចាក់ទឹកដែលគ្មានលូស្តុក | 0.9 |
| បង្គន់ស្ងួតដែលមានកំរាលតែគ្មានគំរប | 0.3 |
| បង្គន់ចំហហៀរចេញ | 0.6 |
| ផ្សេងៗ | 0.3 |
| សរុប | 2.1 |

មូលហេតុចម្បងដែលគ្រួសារថា ធ្វើឲ្យខ្លួនគ្មានបង្គន់ប្រើ គឺថ្លៃសាងសង់ខ្ពស់ (៩៧,៨០%) គ្មានសម្ភារៈសំណង់នៅតំបន់ខ្លួនរស់នៅ (២៦%) គ្មានជំនួយពីក្រៅ ដូចជាពី រដ្ឋាភិបាល និង NGOs (១០,៥០%)។ លទ្ធផល FGD បញ្ជាក់ថា ស្ថានភាពហិរញ្ញវត្ថុក្នុងគ្រួសារ ជាមូលហេតុចម្បងមួយនៃការគ្មានបង្គន់ប្រើ។ អ្នកចូលរួមម្នាក់ក្នុង FGD ក្រុមនារីសុទ្ធ បានលើកថា "ការលក់កម្លាំងពលកម្មដើម្បីធ្វើបង្គន់ មិនមែនងាយនោះទេ ព្រោះលុយរកបានវា (ត្រូវចាយ) អស់ទៅវិញជារៀងរាល់ថ្ងៃ"។ ក្រុមប្រឹក្សាឃុំម្នាក់ ក៏លើកឡើងស្រដៀងគ្នាដែរថា "ខ្ញុំមិនដែលឮអ្នកណានិយាយពីការពិបាកប្រើបង្គន់នោះទេ មានតែឮនិយាយពីរឿងលុយកាក់ គឺបើសិនមានលុយ គេអាចធ្វើបង្គន់បានហើយ"។

ចំណុចគួរចាប់អារម្មណ៍មួយ គឺទោះបីមាន ឬគ្មានលុយកាក់យ៉ាងណាក្តី ក៏មេគ្រួសារតែងចូលចិត្តបង្គន់ប្រភេទចាក់ទឹកជានិច្ច។ គ្រួសារគ្មានបង្គន់សព្វថ្ងៃ (៨៦%) តែងជ្រើសយកបង្គន់ប្រភេទចាក់ទឹក ហើយពួកគេនឹងសង់វាមួយបើសិនមានលុយ ដូចបញ្ជាក់ច្បាស់នៅក្នុង FGD ក្រុមនារីសុទ្ធ នៅខេត្តកំពង់ចាម ដែលថា "ខ្ញុំមិនចង់ធ្វើបង្គន់ស្ងួតដែលមានកំរាលតែគ្មានគំរបនោះទេ ព្រោះវាកខ្វក់ពេក។ ខ្ញុំរង់ចាំរហូតដល់ពេលមានលុយគ្រប់ រួចធ្វើបង្គន់ចាក់ទឹកតែម្តង"។

### *ទស្សនៈគ្រួសារអំពីចំណាយសាងសង់បង្គន់*

កម្មវិធីផ្សព្វផ្សាយពីអនាម័យ ដែលឧបត្ថម្ភគាំទ្រដោយ NGOs និងអនុវត្តឡើងដោយរួមសហការជាដៃគូជាមួយ កន្លែងលក់សម្ភារៈសំណង់ឯកជន និងអាជ្ញាធរមូលដ្ឋាន កំពុងមានដំណើរការក្នុងខេត្តសិក្សាទាំង ៥។ ឧទាហរណ៍ អង្គការ Lien Aid កំពុងដំណើរការកម្មវិធីអប់រំ ដោយរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន (មេភូមិ ក្រុមប្រឹក្សាឃុំ) ព្រមទាំងក្រុមជាង និងហាងលក់សម្ភារៈនៅមូលដ្ឋាន ដើម្បីផ្ទេរជំនាញសម្អាតទឹក និងកសាងហេដ្ឋារចនាសម្ព័ន្ធអនាម័យ ទៅឲ្យសហគមន៍នៅតាមមូលដ្ឋាន។ បង្គន់ចាក់ទឹកដែលមានលូបីកង់ និងចានបង្គន់ចាក់ទឹកមួយ មានតម្លៃ ១៦៤.០០០រៀល (៤០ដុល្លារ[២]) រួមទាំងថ្លៃដឹកជញ្ជូនផង។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម បានកត់សំគាល់ថា "ការទិញ (សម្ភារៈសាងសង់បង្គន់មួយឈុត) ពីអង្គការ Lien Aid គឺថោកជាង (ទិញមួយ) ពីប្រភពឯកជន ដែលមានថ្លៃដល់ទៅ ២០០.០០០រៀល (៤៨,៧៨ដុល្លារ) ឬច្រើនជាងនេះ ដោយលូមួយកង់អាចមានថ្លៃខុសគ្នាប្រហែល ១០.០០០រៀល (២,៤៣ដុល្លារ)"។

យោងតាមអង្កេត គ្រួសារនានានៅតែយល់ថា ការសាងសង់បង្គន់មួយត្រូវចំណាយអស់ច្រើនពេក។ ឧទាហរណ៍ គ្រួសារ ១២% ជឿថា បង្គន់មួយត្រូវចំណាយមិនដល់ ១០០ដុល្លារ ទេ ប៉ុន្តែ មានប្រហែល ៧៥% ទៀត យល់ថា ត្រូវចំណាយអស់ដល់ ១០០ ទៅ ៣០០ដុល្លារ ឬលើសពីនេះ ទើបអាចសាងសង់បង្គន់

[២] ១ដុល្លារ ស្មើនឹង ៤១០០រៀល

រូបភាព ១: ការយល់ឃើញពីចំណាយសាងសង់បង្គន់មួយ




សមរម្យមួយបានសម្រាប់គ្រួសារខ្លួន (រូបភាព ១)។ ចំពោះគ្រួសារអ្នកគ្មានបង្គន់ ឧបសគ្គចម្បងដែលរាំងស្ទះការសាងសង់បង្គន់ ប្រហែលជាការមិនមានលុយសន្សំផ្ទាល់ខ្លួនគ្រប់គ្រាន់។ ប្រជាជនជាទូទៅតែងគិតថា ការសាងសង់បង្គន់សមរម្យមួយ ត្រូវចំណាយអស់ច្រើនជាងការពិតជាក់ស្តែងឆ្ងាយណាស់ ដែលធ្វើឲ្យពួកគាត់កាន់តែគ្មានទឹកចិត្តចង់ធ្វើបង្គន់។

ទាក់ទិននឹងកម្ចីផ្តល់ឲ្យដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) សម្រាប់សាងសង់បង្គន់ អ្នកផ្តល់ព័ត៌មានគន្លឹះ (អ្នកភូមិ ក្រុមប្រឹក្សាឃុំ និងមេភូមិ) បានដឹងដោយចោះៗតែប៉ុណ្ណោះ។ ពួកគាត់ភាគច្រើនមិនដឹងថា មានការផ្តល់កម្ចីសម្រាប់ឲ្យធ្វើបង្គន់នោះទេ ប៉ុន្តែមានខ្លះបានដឹងថា MFIs ក៏មានផ្តល់កម្ចីបែបនេះដែរ។ MFIs ជាច្រើនបានចាប់ផ្តើមពង្រីកសេវាកម្មទៅដល់ភូមិ តែកម្ចីទាក់ទងនឹងបញ្ហាអនាម័យ ខាង MFIs និង អ្នកភូមិ មិនសូវបានគិតគូរទេ។ អ្នកភូមិជារឿយៗប្រើកម្ចីបានពី MFIs មកធ្វើវិនិយោគលើការងារស្រែចំការ ប៉ុន្តែគាត់មិនចង់ខ្ចីលុយពី MFIs មកធ្វើបង្គន់ទេ។ ចំពោះសំណួរពីការយល់ឃើញក្នុងការប្រើប្រាស់សេវាកម្ម MFIs ដើម្បីសាងសង់បង្គន់ គ្រួសារ ៩២% មិនចង់ខ្ចីលុយមកធ្វើបង្គន់ទេ ហើយ ៨៣% លើកថា ខ្លាចមិនអាចសងគេវិញឲ្យបានទៀងទាត់តាមលក្ខខណ្ឌកម្ចីតម្រូវឡើងដោយ MFIs។ ការកត់សំគាល់ខាងក្រោមបានពី FGDs និង KIIs បានបញ្ជាក់គាំទ្រដល់ទស្សនៈទាំងនេះ៖

*នៅទីនេះគ្មានអ្នកភូមិណាម្នាក់ បានប្រើកម្ចីពី MFIs មកធ្វើបង្គន់ទេ ...ពីព្រោះ MFIs មិនអនុញ្ញាត ហើយប្រជាជនក៏មិនហ៊ានខ្ចីដែរ ព្រោះខ្លាចអត់លុយសងកម្ចីនោះវិញ...* (មេភូមិសន្ទិចលិច ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)

*NGOs (MFIs) មិនផ្តល់កម្ចីសម្រាប់ធ្វើបង្គន់ទេ... បើយើងចង់ខ្ចី គេឲ្យយើងខ្ចី តែពួកយើងមិនចង់ខ្ចីទេ ព្រោះខ្លាចមិនអាចសងគេវិញ...* (មេភូមិអង្គរជ័យលើ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម)

*[ខ្ញុំ] មិនហ៊ានខ្ចីលុយ ឬប្រើកម្ចីមកសង់បង្គន់ទេ... [ខ្ញុំ] គ្មានមធ្យោបាយសងកម្ចីនោះវិញ ព្រោះបង្គន់មិនអាចផ្តល់ជាប្រាក់ចំណូលអ្វីបាន...* (នារីមកពីភូមិសន្ទិចលិច ឃុំដងក្តារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)

*[ខ្ញុំ] មិនដែលគិតរកខ្ចីលុយមកសង់បង្គន់ ឬទិញពាងចម្រោះទឹកទេ ព្រោះ [ខ្ញុំ] ខ្លាចអស់ដីស្រែ...* (ឪពុកមានកូនបួននាក់ នៅភូមិត្រពាំងស្លា ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម)

### ***ចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់គ្រួសារ ក្នុងបញ្ហាទឹកហូបស្អាត សុខភាព និងអនាម័យ***

ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍និងវិទ្យុ) ជាប្រភពសារឬព័ត៌មានដ៏សំខាន់របស់គ្រួសារនានា បន្ទាប់មកមាន ការប្រជុំក្នុងសហគមន៍ (រួមទាំងការបណ្តុះបណ្តាលក្នុងសហគមន៍) ដែលជាច្រកមួយដ៏មានប្រសិទ្ធភាព សម្រាប់ផ្សព្វផ្សាយសារអំពីអនាម័យ និងទឹកស្អាត ទៅដល់បណ្តាសហគមន៍នៅជនបទ។ ក្នុងឆ្នាំកន្លងទៅ គ្រួសារបានដឹងឬបានទទួលព័ត៌មានផ្សព្វផ្សាយអំពី ទឹកហូបស្អាត (៥៧,៩០%) ការធ្វើបង្គន់ (៣៦%) និង ការលាងដៃនឹងសាប៊ូ (៣២,៧០%)។

ជាទូទៅ គ្រួសារនានាបានអនុវត្ត S&H ពាក់ព័ន្ធនឹង ទឹកស្អាត (៨០%) អនាម័យនិងការសម្អាតដៃ (៦៤%) អនាម័យម្ហូបអាហារ (៤៤%) និងមានការយល់ដឹងពីរបៀបរក្សា S&H ឲ្យបានល្អ។ គ្រួសារ ដែលមានចំណេះដឹងពីការរាលដាលជំងឺរាគរូស និងការបង្ការ ក៏មានច្រើនគួរកត់សំគាល់ដែរ។ ពួកគេបានដឹងថា ជំងឺរាគឆ្លងតាមម្ហូបអាហារមិនស្អាត (៦៧%) ទឹកមិនស្អាត (៦៧%) សត្វរុយ (៦០%) ដៃកខ្វក់ (៤៨%) និងមាន ១៧% ដឹងថា វាអាចឆ្លងតាមការបន្ទោរបង់ពាសវាលពាសកាល (OD)។

ចំណេះដឹងអំពី S&H វាជាប់ទាក់ទងច្រើនទៅនឹងកម្រិតអប់រំរបស់មេគ្រួសារ។ ដោយប្រើទំនាក់ទំនង Spearman កម្រិតអប់រំរបស់មេគ្រួសារជាប់ទាក់ទងជាវិជ្ជមាន[៣] ជាមួយនឹងការយល់ដឹងរបស់គាត់ពីរបៀបឆ្លងជំងឺរាគ ហើយក៏ជាប់ទាក់ទងជាវិជ្ជមានជាមួយនឹង ចំណេះដឹងរបស់គ្រួសារអំពីការរាលដាលជំងឺរាគនៅកម្រិត ៥% ដោយមានមេគុណទំនាក់ទំនង (correlation coefficient) 0.085។ តួលេខនេះបញ្ជាក់ថា មេគ្រួសារមានកម្រិតអប់រំខ្ពស់កាលណា សមាជិកគ្រួសារក៏មានការយល់ដឹងបានច្រើនកាលនោះពីគោលបំណងនៃ S&H បានអនុវត្ត S&H ទៀងទាត់ល្អ និងដឹងពីវិធីបង្ការជំងឺរាគ។ លើសពីនេះ មេគ្រួសារតែងមើលឃើញការរក្សាសុខភាពបានល្អ ដូចជាការបញ្ចៀសជំងឺគម្លាត់ និងការបង្ការជម្ងឺឆ្លង (៩៤%) ជាមូលហេតុសំខាន់សម្រាប់រក្សាស្តង់ដារ S&H ឲ្យបានល្អ។ ពួកគេក៏បានដឹងពីផលប្រយោជន៍នៃការលាងដៃ ប៉ុន្តែការយល់ដឹងពីពេលសំខាន់ៗដែលត្រូវលាងដៃ វាប្រែប្រួលខុសគ្នា ទៅតាមមុខរបរពួកគេ៖ មេគ្រួសារជានារីតែងយល់ដឹងបានច្រើនជាង ពីតម្រូវការលាងដៃនៅមុនពេលរៀបចំនិងចម្អិនម្ហូបអាហារ ចំណែកអ្នកឯទៀតឆ្លើយថា ពេលសំខាន់បំផុតដែលត្រូវលាងដៃ គឺនៅមុននិងក្រោយពេលបរិភោគអាហារ និងក្រោយពេលទៅបន្ទោរបង់។

ចំណេះដឹងរបស់គ្រួសារអំពីការស្តុកទឹក និងការធ្វើឲ្យទឹកស្អាតអាចហូបបាន ក៏មានកម្រិតខ្ពស់ដែរ។ មូលហេតុសំខាន់ដែលគ្រួសារលើកឡើងពីតម្រូវការស្តុកទឹកទុក គឺដើម្បីបង្ការការឆ្លងចូលមេរោគ (៧៥%) ការរក្សាទឹកទុកឲ្យបានស្អាត (២៣%) និង

---

[៣] Significant នៅកម្រិត ១% ដោយមាន correlation coefficient 0,165

មានសុវត្ថិភាព (១៩%)។ ពួកគេក៏បញ្ជាក់ដែរថា ចំណាត់ការធ្វើឲ្យទឹកស្អាតអាចហូបបាននេះ គឺត្រូវធ្វើយ៉ាងណាកុំឲ្យមានមេរោគ ធូលី ឬលាមកធ្លាក់ចូលទឹក (៦២,៣០%) ដើម្បីរក្សាសុខភាពឲ្យបានល្អ (៥០%) និងបង្ការជំងឺផ្សេងៗ (១៩%)។

### *ការទទួលយករបស់គ្រួសារនូវការហូបទឹកស្អាត និងអនុវត្តវិធីអនាម័យ*

ជាការប្រសើរបំផុត ការលាងដៃគួរក្លាយជាទម្លាប់តែម្ដង មិនមែនជាទង្វើម្ដងម្កាលនោះទេ។ ពួកអ្នកចូលរួមក្នុង FGD និង KIIs រាយការណ៍ថា ពួកគេច្រើនលាងដៃតែនៅមុនពេលបរិភោគ ជាពិសេស ក្រោយពេលចុះធ្វើការក្នុងស្រែ ក្រោយពេលទៅបង្គន់ (បន្ទោរបង់) និងនៅពេលដៃកខ្វក់។ ទោះយ៉ាងនេះក្ដី ពួកកុមារទំនងលាងដៃបានច្រើនជងជាងមនុស្សពេញវ័យ។ ឧទាហរណ៍ម្ដាយក្នុងគ្រួសារមួយបញ្ជាក់ថា "ពួកកូនៗលាងដៃបានល្អជាងខ្ញុំ និងប្ដីខ្ញុំ។ ពួកគេតែងសួរថា តើលាងដៃហើយឬនៅ?"។ រឿងនេះប្រហែលមកពី លោក/អ្នកគ្រូ តែងរំលឹកពួកកុមារជាប្រចាំអំពី S&H ជាពិសេស សារៈសំខាន់នៃការលាងដៃ។ សិស្សសាលាពន្យល់ថា "លោក/អ្នកគ្រូ ណែនាំពួកយើងឲ្យលាងដៃបានទៀងទាត់ នៅមុនពេលនិងក្រោយពេលញ៉ាំហើយត្រូវលាងដៃនឹងសាប៊ូក្រោយពេលបោសសម្រាម ឬបោសដី...។ នាយកសាលាម្នាក់លើកបន្ថែមថា "សិស្សសាលាតែងលាងដៃ ពីព្រោះសាលារៀនបានតម្រូវដូច្នេះ"។

គំហើញបានពី FGD និង KIIs បញ្ជាក់គាំទ្រដល់អង្កេតដែលបានសង្កេតឃើញថា ប្រជាជនលាងដៃជាមួយតែទឹក ឬសាប៊ូ និងទឹក និងមានតិចនាក់ណាស់ដែលប្រើផេះ។ គ្រួសារដែលលាងដៃតែនឹងទឹក បានលើកថា ថ្លៃសាប៊ូជាឧបសគ្គរាំងការអនុវត្តលាងដៃនឹងសាប៊ូ។ រឿងនេះមានបញ្ជាក់ក្នុងការពិភាក្សារបស់ក្រុមនារីសុទ្ធ ដែលថា "បើ [យើង] លាងដៃនឹងសាប៊ូ [យើង] ត្រូវចំណាយលុយទិញសាប៊ូ ដូច្នេះ [គួរ] ទុកលុយទិញប្រីចេងមកប្រើ បានពីរថ្ងៃវិញ"។ អ្នកចូលរួមម្នាក់ទៀតបន្ថែមថា "ពីមុនម្សៅសាប៊ូមានលក់ជាកញ្ចប់តូចថ្លៃត្រឹម ១០០រៀលប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះត្រូវតែទិញច្រើនជាងមុនដល់ ៥០០រៀល/កញ្ចប់ ឬច្រើនជាងនេះទៀត"។ បុគ្គលិកមណ្ឌលសុខភាពបានលើកពីក្ដីបារម្ភចំពោះអាកប្បកិរិយារបស់សហគមន៍ថា "សាប៊ូមាននៅគ្រប់គ្រួសារ ប៉ុន្តែគេមិនលាង... ពួកគេ (អ្នកភូមិ) តែងនិយាយជាញឹកញាប់ថា មិនដែលលាងដៃមែន តែមិនដែលឃើញមានបញ្ហាអ្វីផង"។

មានគ្រួសារប្រហែល ៨២% បានសម្អាតទឹកសម្រាប់ហូប តាមការដាំឲ្យពុះ (៩០,៥%) ឬប្រើធុងចម្រោះ (១០%)។ ពួកគេជឿថា ការធ្វើទឹកឲ្យស្អាត ជាចំណុចល្អដើម្បីថែទាំសុខភាព រីឯអ្នកដែលមិនធ្វើដូច្នោះបានពន្យល់ថា មកពី "គ្មានពេល" ដាំទឹក។ គ្រួសារមួយភាគតិច បានប្រកាន់ខ្ជាប់ទំលាប់មិនដាំទឹក ឬសម្អាតទឹកសម្រាប់ហូប ព្រោះពួកគេគ្មានទម្លាប់នេះ។ ការយល់ឃើញថា ទឹកឆៅវាល្អសម្រាប់សុខភាពនេះ ជាកត្តាមួយទៀតដែលធ្វើឲ្យគ្រួសារ មិនសូវចង់សម្អាតទឹកសម្រាប់ហូប។ ឧទាហរណ៍ គ្រូបង្រៀនថ្នាក់បឋមសិក្សាម្នាក់បានលើកថា "ពួកអ្នកភូមិមិនជឿ (លើការដាំទឹក) ទេ។ ពួកគេនិយាយថា យើងធ្លាប់ផឹកទឹកក្នុងដានជើងគោ តាំងពីដូនតា មកម្លេះ"។

### *អាកប្បកិរិយារបស់គ្រួសារចំពោះការហូបទឹកស្អាត និងអនុវត្តវិធីអនាម័យ*

លទ្ធផលការសិក្សាបញ្ជាក់ថា គ្រួសារភាគច្រើនមានអាកប្បកិរិយាគាំទ្រការហូបទឹកស្អាត ការលាងដៃ ជាពិសេស ការប្រើបង្គន់មានអនាម័យល្អ ទោះបីគ្រួសារខ្លះនៅអនុវត្តផឹកទឹកឆៅតាមទំលាប់ និងមិនទាន់ទម្លាប់ខ្លួនលាងដៃក្ដី។ គ្រួសារប្រហែល ៨២% បានសម្អាតទឹក ដោយដាំពុះ ឬច្រោះ។ ស្ទើរគ្រប់មេគ្រួសារបញ្ជាក់ថា ទម្លាប់លាងដៃ ជាមួយតែទឹក ឬជាមួយទឹកនិងសាប៊ូឃើញមានជាទូទៅ។ គ្រួសារអ្នកមានបង្គន់ តែងប្រើបង្គន់ផ្ទាល់ខ្លួន ឬបង្គន់សាធារណៈ រីឯគ្រួសារអ្នកគ្មានបង្គន់ភាគច្រើនតែងបន្ទោរបង់ពាសវាលពាសកាល (OD) (៦៥%) ឬដោយជីកកប់ (២៣%)។

## សន្និដ្ឋាន

គ្រួសារនៅតាមជនបទ មានចំណេះដឹងខ្ពស់ពីបញ្ហាអនាម័យ សុខភាព ការហូបទឹកស្អាត និងការស្ដុកទឹក។ អាកប្បកិរិយាចំពោះការទទួលយកការអនុវត្ត S&H ការហូបទឹកស្អាត និងជាពិសេស ការប្រើបង្គន់អនាម័យ មានលក្ខណៈវិជ្ជមាន ទោះបីមានគ្រួសារខ្លះនៅតែអនុវត្ត ការហូបទឹកឆៅតាមទំលាប់ពីបុរាណ និងមិនលាងដៃឲ្យបានទៀងទាត់តាមវិធានការ S&H។

គ្រួសារមានបង្គន់អនាម័យ តែងថែរក្សាវាឲ្យដំណើរការបាន ហើយសមាជិកគ្រួសារតែងប្រើប្រាស់វាជានិច្ច។ គ្រួសារអ្នកគ្មានបង្គន់អនាម័យ តែងបន្ទោរបង់ពាសវាលពាសកាល ឬជីកកប់ ដោយប្រើកន្លែងទាំងនេះ ទាំងនៅរដូវវស្សា និងរដូវប្រាំង។ បង្គន់ចាក់ទឹកជាប្រភេទពេញនិយមជាងគេ ទោះជាគ្រួសារមានធនធានតិចឬច្រើនក្ដី ប៉ុន្តែចំណាប់អារម្មណ៍ថា ការសាងសង់បង្គន់ត្រូវចំណាយអស់ច្រើនពេក ធ្វើឲ្យប្រជាជនមិនចង់ទាំងគិតគូរពីការធ្វើបង្គន់ផង។ គ្រួសារភាគច្រើនតែងប្រើបង្គន់សាធារណៈនៅពេលទៅកន្លែងសាធារណៈ ដូចជា វត្ត ឬសាលារៀន។ រឿងនេះបង្ហាញថា ការមានបង្គន់ពុំមានទាស់ខុសអ្វីទេ ហើយបញ្ជាក់គាំទ្រដល់លទ្ធផលរកឃើញថា ចំណាយ និងការយល់ឃើញពីចំណាយខ្ពស់ ជាឧបសគ្គចម្បងចំពោះការសាងសង់បង្គន់។ គ្រួសារនានារារែកជាខ្លាំងក្នុងការប្រើកម្ចី MFIs ដើម្បីសាងសង់បង្គន់ ពីព្រោះមិនមែនគ្រាន់តែ ខ្លាចមិនអាចបំពេញបានតាមលក្ខខណ្ឌសងកម្ចីវិញនោះទេ ប៉ុន្តែវិនិយោគលើបង្គន់ក៏គ្មានផ្ដល់ជាប្រាក់ចំណូលអ្វីដែរហើយចំណុចនេះបង្ហាញថា ការរកចំណូលដោះស្រាយជីវភាពប្រចាំថ្ងៃ មានអាទិភាពខ្ពស់ជាង ការមានអនាម័យល្អ។ អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់បានអះអាងថា គាត់នឹងសន្សំប្រាក់ធ្វើបង្គន់ បើសិនអាចរកបានគ្រប់គ្រាន់ សម្រាប់ដោះស្រាយតម្រូវការចំណាយប្រចាំថ្ងៃ និងសន្សំ បានមួយចំនួន។ ស្ទើរគ្រប់គ្រួសារបានដឹងពីផលប្រយោជន៍នៃការលាងដៃ ប៉ុន្តែការយល់ឃើញថាត្រូវលាងដៃនៅពេលណាវាជាប់ទាក់ទងនឹងមុខរបររបស់ពួកគេ។ស្ទើរគ្រប់គ្រួសារបានបញ្ជាក់ថា ទម្លាប់លាងដៃ ជាមួយតែទឹក ឬជាមួយទឹកនិងសាប៊ូ ឃើញមានអនុវត្តជាទូទៅ នៅមុនពេល និងក្រោយពេលបរិភោគ ក្រោយពេលទៅបន្ទោរបង់ និងនៅពេលដៃកខ្វក់។ ពួកកុមារច្រើនលាងដៃបានញឹកញាប់ជាង ពីព្រោះ S&H ជាផ្នែក

មួយនៃកម្មវិធីរបស់សាលារៀន ហើយលោក/អ្នកគ្រូ តែងរំលឹកសិស្សជាប្រចាំអំពីសារៈសំខាន់ នៃការលាងដៃ។

គ្រួសារភាគច្រើនបានសម្អាតទឹកសម្រាប់ហូប ដោយដាំពុះ ឬច្រោះ ដើម្បីរក្សាសុខភាពឲ្យបានល្អ និងបានដឹងពីការស្តុកទឹកទុកឲ្យស្អាត ដើម្បីបង្ការការឆ្លងមេរោគចូល។

## អនុសាសន៍

ថ្វីបើ ដំណោះស្រាយអំពីសេវាអនាម័យគ្របដណ្តប់ ក៏ដូចជាការទទួលបាននូវទឹកស្អាតសម្រាប់ហូប និងប្រើប្រាស់ និងការមានបង្គន់ផ្ទាល់ខ្លួននៅតាមតំបន់ជនបទ នៅមានកម្រិតនៅឡើយ ការលើកកម្ពស់អនាម័យតាមរយៈការផ្ញើសារអំពី S&H និងការលើកទឹកចិត្ត ប្រជាជនឲ្យទទួលអនុវត្ត S&H ជាប្រចាំ អាចជួយឲ្យប្រជាជននៅជនបទ អាចថែទាំសុខភាពរបស់ខ្លួន បានអស់ពីកម្លាំងកាយ ក៏ដូចជាអាចរក្សាចំណូលក្នុងគ្រួសារតាមរយៈការកាត់បន្ថយចំណាយលើសុខភាព។ ដោយផ្អែកលើលទ្ធផលនៃអង្កេត មានសកម្មភាពមួយចំនួនដូចខាងក្រោម ដែលគួរពិចារណាដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងផែនការ៖

- គួររចនារៀបចំកម្មវិធីផ្សព្វផ្សាយ ជំរុញការផ្លាស់ប្តូរអាកប្បកិរិយាមួយ ដោយផ្តោតលើគ្រួសារមួយភាគតូចដែលមិនទាន់ទទួលអនុវត្ត S&H និងជំរុញការទទួលយកជាសាធារណៈ និងការប្រើប្រាស់ទឹកស្អាត និងស្តុកទឹកឲ្យស្អាត។
- ផ្តល់អាទិភាពដល់ការផ្សព្វផ្សាយកម្មវិធីអប់រំ S&H ជាសាធារណៈ ក្នុងនេះ វិទ្យុ និងទូរទស្សន៍ ជាច្រកសំខាន់សម្រាប់ផ្តល់ព័ត៌មាន និងលើកទឹកចិត្តប្រជាជនគ្រប់គ្នាទោះមានកម្រិតអប់រំទាប ឬខ្ពស់ក្តី។
- លើកកម្ពស់ការបណ្តុះបណ្តាលមានការរចនារៀបចំល្អ ដល់សហគមន៍ ឲ្យក្លាយជាប្រភពទី២ នៃសារផ្សព្វផ្សាយលើកកម្ពស់អនាម័យ និងការប្រើទឹកស្អាត និងត្រូវរំលឹកប្រជាជនជាប់ជានិច្ចពី ផលប្រយោជន៍នៃការអនុវត្ត S&H ។
- ធ្វើការងារបន្តពីអន្តរាគមន៍ផ្សេងៗក្នុងពេលកន្លងមកដែលបានផ្តល់កម្ចីសម្រាប់សាងសង់បង្គន់ ក្នុងទម្រង់ជាក្រុមសន្សំ ហើយគួររៀបចំនិងបង្កើតគម្រោងការស្រដៀងគ្នាផ្សេងទៀត សម្រាប់សហគមន៍ និងគ្រួសារដែលមិនអាចទទួលបានកម្ចី ពី MFIs។

## ឯកសារយោង

Council for the Development of Cambodia (2011), "Statement of the Rural Water Supply and Sanitation Sector in the Kingdom of Cambodia", available at <http://www.cdc-crdb.gov.kh/cdc/first_cdcf/session1/statement_rwss_eng.htm> (accessed 1 February 2012)

Ministry for Rural Development (2010), *National Sanitation and Hygiene Knowledge, Attitudes and Practices (KAP) Survey: Final Report* (Phnom Penh: Department of Rural Health Care, MRD)

Mom Chan Dara Soleil (2011), "Improving Rural Sanitation and Hygiene in Rural Cambodia", [online] Agence Kampuchea Press (AKP) 23 March 2012, available at <http://www.akp.gov.kh/?p=3834> (accessed 1 February 2012)

Rosenboom, J.W., C. Jacks, K. Phyrum, M. Roberts & T. Baker (2011), "Sanitation marketing in Cambodia", *Journal of Waterlines,* Vol. 30, No.1, pp. 21-40

World Bank (2008), *Economic Impacts of Sanitation in Cambodia: A five country study conducted in Cambodia, Indonesia, Lao PDR, the Philippines and Vietnam under the Economics of Sanitation Initiative (ESI)* (Jakarta: World Bank)

---

*តពីទំព័រ ៩* **ឥណទានសម្រាប់...**

បណ្តុះបណ្តាលពីជំនាញធ្វើអាជីវកម្ម កសិករមានលទ្ធភាពកាន់តែប្រសើរក្នុងការប្រើប្រាស់កម្ចីបានពី MFIs ឲ្យមានប្រសិទ្ធភាព និងជោគជ័យ។ NGOs និងដៃគូអភិវឌ្ឍន៍នានា អាចដាក់បញ្ចូលវិធានការទាំងនេះទៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន។

***ពង្រីកនូវកម្មវិធីគាំពារសង្គម៖*** ដោយងាយរងគ្រោះជាខ្លាំងនឹងការប៉ះទង្គិចផ្សេងៗ ប្រជាជនក្រីក្រតែងពឹងផ្អែកលើការខ្ចីបុលនៅពេលប្រាក់ចំណូលត្រូវតឹងតែងខ្លាំង ទោះបីមានហានិភ័យខ្ពស់នៃការធ្លាក់ខ្លួនជំពាក់បំណុលកាន់តែច្រើនក្តី។ កំណើនវិនិយោគក្នុងកម្មវិធីគាំពារសង្គម អាចជួយកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះក្នុងចំណោមអ្នកក្រ និងជួយការពារពួកគេកុំឲ្យធ្លាក់ខ្លួនជំពាក់បំណុល។

## ឯកសារយោង

Agrifood Consulting International (2005), Final Report for the Cambodia Agrarian Structure Study, prepared for the Ministry of Agriculture, Forestry and Fisheries, Royal Government of Cambodia, the World Bank, the Canadian International Development Agency (CIDA) and the Government of Germany/Gesellschaft für Technische Zusammenarbeit (GTZ) (Bethesda, MA: ACI)

Cambodia Microfinance Association (2011), Microfinance Information Exchange (Phnom Penh: CMA)

Kim S (2001), "Reciprocity: Informal Patterns of Social Interactions in a Cambodian Village", master's thesis, Northern Illinois University, Illinois

MLMUPC (2011), Land Adminstration Sub Sector Program Newsletter, Issue 1(Phnom Penh: Ministry of Land Management Urban Planning and Construction (MLMUPC))

*តទៅទំព័រ ២១*

*តពីទំព័រ ៥* **បញ្ហាប្រឈម...**

UK; New York: Cambridge University Press)

MAFF (2009), *Cambodia's National Forest Programme: Framework Document, 4th Draft* (Phnom Penh: MAFF)

MAFF (2012), *Draft of National Action Program to Combat Land Degradation in the Kingdom of Cambodia 2011-2020* (Phnom Penh: MAFF)

MoE (2002), *Cambodia's Initial National Communication* (Phnom Penh: MoE)

MoE & UNDP (2011), *Building Resilience: The Future for Rural Livelihoods in the Face of Climate Change, Cambodia Human Development Report 2011* (Phnom Penh: MoE & UNDP)

MoP (2010), *Achieving Cambodia's Millennium Development Goals* (Phnom Penh: MoP)

MOWRAM (2011), *Draft Sub Decree on River Basin Management* (Phnom Penh: MOWRAM)

MRC (2009), *Adaptation to Climate Change in the countries of the Lower Mekong Basin,* MRC Technical Paper No 24,http://www.mrcmekong.org/assets/Publications/report-management-develop/MRC-IM-No1-Adaptation-to-climate-change-in-LMB.pdf (accessed 12 July 2012) (MRC: Ventiane)

MRC (2010), *Technical Note 10. Assessment of Basin-wide Development Scenarios: Impacts on the Tonle Sap Ecosystem* : MRC

Nang P. & Yem D. (2010), *Sustainable Pathways for Attaining the Millennium Development Goals: Cambodia Case Study.* ACDRI Special Report (Phnom Penh: CDRI)

RGC (2010a), *Achieving Cambodia's Millennium Development Goals. Updated 2010* (Phnom Penh: MoP)

RGC (2010), *Cambodia Post-Ketsana Disaster Needs Assessment. Part I: Main Report,*http://www.gfdrr.org/gfdrr/sites/gfdrr.org/files/GFDRR_Cambodia_PDNA_2010_EN.pdf (accessed 9 August 2012) (Phnom Penh: CNCDM)

RGC (2012), *Flood 2011 Report* (Phnom Penh: CNCDM)

Ros B., Nang P. & Chhim C. (2011), *Agricultural Development and Climate Change: The Case of Cambodia,*Working Paper Series No. 65 (Phnom Penh: CDRI)

Saad-Filho, Alfredo (2010), *Growth, Poverty and Inequality: From Washington Consensus to Inclusive Growth,* DESA Working Paper No. 100 (New York:UN-Department of Economic and Social Affairs),http://www.un.org/esa/desa/papers/2010/wp100_2010.pdf (accessed 10 June 2012)

So S., B.D. Ratner, K. Mam & S. Kim (2011), *Conflict and Collective Action in Tonle Sap Fisheries: Strategic Priorities to Improve Governance and Support Community Livelihoods,* Policy Brief (drafted) (Phnom Penh: CDRI)

UNEP (2012), "Environment and Development Challenges: The Impartive to Act", paper presented at the 12th UNEP Governing Council meeting, Nairobi, Kenya, 20 February 2012, http://www.nfp-facility.org/21398-0-0.pdf (accessed 2 August 2012)

UNESCAP (2008), *Monitoring and Reporting Progress on Community-Based Disaster Risk Management in Cambodia*(Bangkok: Asian Disaster Preparedness Center). http://www.adpc.net/v2007/programs/CBDRM/Publications/Downloads/Publications/Cambodia_Update.pdf (accessed 2 August 2012)

USAID (2005), *Livelihoods and Conflict: A Toolkit for Intervention* http://www.adpc.net/v2007/programs/CBDRM/INFORMATION%20RESOURCE%20CENTER/CBDRM%20Publications/2008/final_crcambodia_23nov.pdf (accessed 12 July 2012)

Vong, S. & Michael Dutschke (2009), Integrate Climate Change Issues into the National Forest Programme in Cambodia, background paper for National Workshop, Phnom Penh

Women's Environmental Network (2010), *Gender and the Climate Change Agenda: The impacts of Climate Change on Women and Public Policy* (London: WEN)

*តពីទំព័រ ១៤* **ឥណទានសម្រាប់ ...**

NIS (2008), National census map layers and database (Phnom Penh: NIS)

Ovesen, J., I.B. Trankell, Heng K. & Sochoeun C. (2012), *Rice Farming and Microcredit in Takeo* (Phnom Penh: Uppsala University and Intean Poalroath Rongroeurng Ltd)

Phlong P. (2009), "Informal Credit Systems in Cambodia", master's thesis, Nothern Illinois University, Illinois

UNCDF (2011), *Takeo Provincial Development Outlook* (Phnom Penh: UNCDF)

World Bank (2007), *Sharing Growth: Equity and Development in Cambodia* (Phnom Penh: World Bank for the Cambodia Development Cooperation and Forum)